# សិស្សទី ២

សូមសរសេរពាក្យ *គ្រឹះ* នៅលើក្រដាសមួយសន្លឹក ហើយបង្រៀនវាដល់ក្រុមរបស់អ្នក ។

- ហេតុអ្វីគ្រឹះគឺជាផ្នែកមួយដ៏សំខាន់នៃអគារ ?
- តើមានអ្វីនឹងកើតឡើង ប្រសិនបើគ្រឹះនោះមានបញ្ហា ?

សូមអញ្ជើញសមាជិកក្រុមរបស់អ្នកម្នាក់ឲ្យអាន កូរិនថូសទី១ ៣:១០ ឮៗ ហើយសួរសមាជិកក្រុមផ្សេងទៀតឲ្យរកមើលថា ប៉ុលបាននិយាយអ្វីខ្លះអំពីកិច្ចការផ្សព្វផ្សាយសាសនារបស់លោកនៅក្នុងចំណោមពួកកូរិនថូស ។

- តើប៉ុលបាននិយាយថា លោកបានធ្វើអ្វីខ្លះ កាលធ្វើជាអ្នកផ្សព្វផ្សាយសាសនាម្នាក់នៅកូរិនថូស ?
- តើអ្នកគិតថា ប៉ុលចង់មានន័យដូចម្ដេច នៅពេលលោកមានប្រសាសន៍ថា « មានម្នាក់ទៀតជាអ្នកសង់ពីលើ » ?

សូមអញ្ជើញសមាជិកក្រុមរបស់អ្នកម្នាក់ទៀតអាន កូរិនថូសទី១ ៣:១១ ឮៗ ហើយសួរសមាជិកក្រុមផ្សេងទៀតឲ្យរកមើលថា ប៉ុលបានសង់គ្រឹះអ្វីសម្រាប់ពួកបរិសុទ្ធនៅកូរិនថូស ។

- តើប៉ុលបានសង់គ្រឹះអ្វី កាលលោកបានបង្រៀននៅកូរិនថូស ?
- យោងតាម ខទី ១១ តើនរណាគប្បីធ្វើជាគ្រឹះនៃជីវិតរបស់យើង ? ( សូមប្រាកដថា ក្រុមអ្នកស្គាល់ពីសេចក្ដីពិតដូចតទៅនេះ ៖ ព្រះយេស៊ូវគ្រីស្ទគឺជាគ្រឹះដែលយើងត្រូវសង់លើ ។ សូមពិចារណាអញ្ជើញក្រុមរបស់អ្នកឲ្យគូសចំណាំសេចក្ដីពិតនេះនៅក្នុង ខទី ១១ ) ។
- តើការសង់នៅលើគ្រឹះរបស់ព្រះយេស៊ូវគ្រីស្ទអាចជួយយើងឲ្យស៊ូទ្រាំនឹងការល្បួង និងការសាកល្បងបានដោយរបៀបណា ? ( សូមមើល ហេលេមិន ៥:១២ ) ។
- តើយើងអាចធ្វើឲ្យប្រាកដថា ជីវិតរបស់យើងត្រូវបានសង់នៅលើគ្រឹះនៃព្រះយេស៊ូវគ្រីស្ទបានយ៉ាងដូចម្ដេច ?

សូមអញ្ជើញសមាជិកក្រុមម្នាក់ឲ្យចែកចាយអំពីមនុស្សម្នាក់ដែលគាត់ស្គាល់ ហើយមានជីវិតឆ្លុះបញ្ចាំងពីការសង់លើគ្រឹះនៃព្រះយេស៊ូវគ្រីស្ទ ។ ចូរសុំឲ្យសិស្សម្នាក់នេះពន្យល់ពីរបៀបដែលការសង់គ្រឹះលើព្រះគ្រីស្ទបានប្រទានពរដល់បុគ្គលម្នាក់នេះ ។

សូមអញ្ជើញសមាជិកក្រុមឲ្យដាក់គោលដៅមួយ ដែលនឹងជួយគាត់ឲ្យសង់លើគ្រឹះនៃព្រះយេស៊ូវគ្រីស្ទ ។



© 2015 by Intellectual Reserve, Inc. All rights reserved.